METHODFINDER



www.MethodFinder.net

# Practitioner's Guide:

## ការរៀបចំកសាងផែនការតាមបែបការចូលរួម

Deutsche Gesellschaft für Technische Zusammenarbeit (GTZ) GmbH

Bundesministerium für wirtschaftliche Zusammenarbeit und Entwicklung

Ministry of Land Management, Urban Planning and Construction

Copyright: Royal Government of Cambodia – GTZ supported: Land Administration and Management Project (LMAP)

Concept and Layout: Nikolaus Schall / Michael Becker

# ការរៀបចំកសាងផែនការតាមបែបការចូលរួម

## បទអត្ថាធិប្បាយសង្ខេប :



ឧបករណ៍និង បច្ចេកទេសនៃការរៀបចំកសាងផែនការតាមបែបការចូលរួមជួយដល់សិក្ខាកាមមានឥទ្ធិពល និង រួមចំណែកត្រួតពិនិត្យលើការផ្តួចផ្តើមអភិវឌ្ឍន៍ និងសេចក្តីសំរេចនានាអំពីការងារនោះ។ នៅក្នុងការរៀបចំកសាងផែន ការអភិវឌ្ឍន៍ការចូលរួមគឺជាដំណើរការនៃការចូលរួមចំណែកប្រកបដោយសមធម៌ និងយ៉ាងសកម្មលើគ្រប់ភាគីពាក់ ពន្ធ័ទាំងអស់នៅក្នុងការកសាងគោលនយោបាយអភិវឌ្ឍន និងយុទ្ធសាស្ត្រព្រមទាំងក្នុងការវិភាគ ការរៀបចំកសាង ផែនការការអនុវត្តន៍ ការត្រួតពិនិត្យតាមដាន និងការវាយតំលៃអំពីសកម្មភាពអភិវឌ្ឍន៍ ។ ភាគីពាក់ពន្ធ័ដែលមានភាព ទន់ខ្សោយចាំបាច់ត្រូវតែមានការផ្តល់អំណាច ដើម្បីបង្កើន នូវចំណេះដឹងរបស់ពួកគេនូវឥទ្ធិពល និងការត្រួតពិនិត្យលើ ជីវភាពរស់នៅរបស់ពួកគេផង ដែរ រួមទាំង គំនិតផ្តួចផ្តើមអភិវឌ្ឍន៍នានា ដែលពាក់ពន្ធ័នឹងពួកគេដើម្បីបង្កើនឱ្យមាននូវ ដំណើរការអភិវឌ្ឍន៍ឱ្យកាន់ តែមានសមធម៌ថែមទៀត ។

ការចូលរួមគឺជាការខិតខំមានការរៀបចំត្រឹមត្រូវនៅក្នុងស្ថាប័ន និងរចនាសម្ពន្ធ័ដើម្បីបង្កើនលទ្ធភាពរបស់ភាគីពាក់ពន្ធ័ និងការត្រួតពិនិត្យទៅលើធនធាននិងការសំរេចពាក់ពន្ធ័ផ្សេងៗដែលរួមចំណែកដល់ជីវភាពរស់នៅមួយប្រកប ដោយចេរភាព។ លើសពីនេះទៀតការចូលរួមត្រូវបានចាត់ទុកថាជាដំណើរការសារចុះ សារឡើង ភ្ជាប់ទៅនឹងការវាយតំលៃឡើងវិញច្រើនដង និងជាប្រចាំនៃទំនាក់ ទំនងរវាងភាគីខុសៗគ្នានៅក្នុងសង្គមស៊ីវិលដើម្បីបង្កើនការត្រួតពិនត្យ និងឥទ្ធិពលរបស់ភាគីពាក់ពន្ធ័ទៅលើគំនិតផ្តួចផ្តើមអភិវឌ្ឍន៍នានាដែលមានឥទ្ធិពលលើជីវិតរស់ នៅរបស់ពួកគេ ។

Copyright: Royal Government of Cambodia – GTZ supported:
Land Administration and Management Project (LMAP)

# ការរៀបចំកសាងផែនការតាមបែបការចូលរួម



## អ្នកដែលអាចប្រើប្រាស់វិធីសាស្ត្រនេះសំខាន់ជាងគេ

អ្នករៀបចំកសាងផែនការសង្គម និងទីក្រុង ជំនាញការផ្នែកវិស័យឯកជន និងសាធារណៈ ។

## គោលបំណងនៃវិធីនេះ



មានប្រភេទនៃការចូលរួមយ៉ាងច្រើន និងកិរិតរួមទាំងការពិគ្រោះយោបល់សាមញ្ញរហូតដល់ការធ្វើសេចក្តីសំរេចរួមគ្នា និងឈានរហូតដល់ការ រៀបចំគ្រប់គ្រងដោយខ្លួនឯងដោយភាគីពាក់ពន្ធ័ផ្ទាល់ ។ យុទ្ធវិធីនៃការចូលរួមវិធីសាស្ត្រឧបករណ៏សកម្មភាពនានាទាំងអស់នេះអាចចូលរួមដល់ដំណើរការអភិវឌ្ឍន៏តាមបែបការចូលរួមដែលកាន់តែមាន លក្ខណៈសមធមិ និងតាមតំរូវការជាក់ស្តែងខ្ពស់ថែមទៀត ។ការចូលរួមគឺជាកត្តាគន្លឹះសំរាប់ចេរភាពនៃគ្រប់គំនិត ផ្តួចផ្តើមអភិវឌ្ឍន៏ពីព្រោះវានាំឱ្យមាននូវ :

- ការកសាងលើសក្តានុពលនិងសមត្ថភាពដែលមានស្រាប់ ការនាំឱ្យមាន នូវ ភាព ជាម្ចាស់នៃផ្នែកនិមួយៗ របស់ភាគីពាក់ពន្ធ័កាន់តែច្រើនឡើង ។
- បង្កើនការយកចិត្តទុកដាក់ទៅលើគោលបំណង និងលទ្ធផល
- ចេរភាពផ្នែកសង្គមរយៈពេលវែង
- បង្កើនសមត្ថភាពនៃការជួយខ្លួនឯងកាន់តែខ្ពស់
- បង្កើននូវភាពខ្លាំង និងមានលក្ខណៈប្រជាធិបតេយ្យនៅក្នុងស្ថាប័ន និងភាពជាដៃគូ

Copyright: Royal Government of Cambodia – GTZ supported:
Land Administration and Management Project (LMAP)

# ការរៀបចំកសាងផែនការតាមបែបការចូលរួម

## ផលប្រយោជន៍

- បញ្ចូលគ្រប់ភាគីពាក់ពន្ធ័សំខាន់ៗនៅក្នុងដំណើការនៃការកំណត់សក្តានុពលភាព និង ឧបសគ្គ័របស់ពួកគេ ។
- ការចូលរួមដោយគ្រប់ភាគីនានាបាននូវការឯកភាពគ្នាក៏រិតខ្ពស់ ។
- ការប្រើប្រាស់នូវវិធីសាស្ត្រនៃការចូលរួមផ្សេងគ្នានិងឧបករណ៏នានាដែលមានដើម្បីឆ្លើយតប ទៅនឹងក្រុម ដែលបានកំណត់ខុសៗគ្នា ។
- វិធីសាស្ត្រនៃការចូលរួមនានាជួយពង្រឹង និងគាំទ្រដល់ការខិតខំប្រឹងប្រែងផ្នែក ប្រជាធិបតេយ្យ ។
- ក្រុមជនជាតិភាគតិចអាចគិតគូរបញ្ចូលកាន់តែមានប្រសិទ្ធិភាពនៅក្នុងដំណើរការអភិវឌ្ឍន៏ ។

## ដែនកំណត់

- រៀបចំដំណើរការចូលរួមសំរាប់ក្រុមធំឬទីតាំងលំនៅដ្ឋានច្រើន គឺអស់តំលៃខ្ពស់ និង ប្រើប្រាស់ធនធាន សកម្មភាពច្រើន ។ ហើយវាក៏ពុំមែនជាការចង់បានផ្នែកនយោបាយដែរ ។
- អាចពិបាកនឹងទទួលបាននូវការឯកភាពគ្នា
- អាចកើតមានឡើងនូវភាពតានតឹងហើយអាចឈានដល់ជម្លោះដែលជាលទ្ធផលនៃដំណើរការចូលរួម
- អ្នកសំរបសំរួលដំណើរការដែលមានសមត្ថភាព ជារឿយៗទាមទារឱ្យធ្វើការសម្រប សម្រួលនូវសកម្មភាព នៃការ ចូលរួម ។
- ដំណើរការនៃការចូលរួមទាមទារឱ្យសាកសួរដលរដ្ឋអំណាចមូលដ្ឋាន ។ កិច្ចការនេះ ចាំបាច់ត្រូវតែច្របាច់បញ្ចូលគ្នាដោយសេចក្តីប្រុងប្រយត្ន័ទៅក្នុងដំណើរការប្រសិន បើពួកគេនឹងចូលរួមប្រកបដោយប្រ សិទ្ធិភាពនោះ ។

Copyright: Royal Government of Cambodia – GTZ supported:
Land Administration and Management Project (LMAP)

# ការរៀបចំកសាងផែនការតាមបែបការចូលរួម

## គោលការណ៍និងដំណើរការទូទៅ



មានទម្រង់បែបបទផ្សេងៗគ្នាជាច្រើនដែលក្នុងនោះការចូលរួមរបស់ប្រជាជនអាចអនុវត្តន៍ទៅបានរួមទាំង :

- **ការចូលរួមដោយប្រយោល:**

  ប្រជាជនចូលរួមដោយត្រូវបានគេប្រាប់នូវអ្វីដែលនិងកើតមានឡើងឬបានកើតមានឬធ្វើសេចក្តីសំរេចនោះទេ ។

- **ការចូលរួមក្នុងការផ្តល់ពត៌មាន:**

  ប្រជាជនចូលរួមដោយការឆ្លើយសំណួរនានាដែលដាក់ឱ្យឆ្លើយដោយអ្នកដែលត្រូវការពត៌មាន។ ជាធម្មតាពួកគេប្រើប្រាស់កំរងសំណួរ ឬ យុទ្ធវិធីស្រដៀងគ្នានេះ ។

- **ការចូលរួមដោយការពិគ្រោះពិភាក្សា :**

  ប្រជាជនចូលរួមដោយមានការពិគ្រោះពិភាក្សា ចំណែកប្រជាជនមកពី ខាងក្រៅស្តាប់ នូវទស្សនះរបស់ពួកគេ ។ ពួកអ្នកជំនាញមកពីខាងក្រៅទាំងនេះកំណត់បញ្ហានិង ដំណោះស្រាយហើយអាចកែសំរួលកត្តាទាំងនេះទៅតាមចំលើយរបស់ប្រជាជន ។

- **ការចូលរួមសំរាប់ការលើកទឹកចិត្តផ្នែកសំភារះ**

  ប្រជាជនចូលរួមដោយផ្តល់នូវធនធានផ្សេងៗឧទាហរណ៍ ផ្តលកំលាំងពលកម្ម ដើម្បីទទួលបានត្រលប់មកវិញនូវ ម្ហូបអាហារជាប្រាក់កាស ឬសំភារះលើកទឹកចិត្តដ៏ទៃទៀត ដូច្នេះការចូលរួមត្រូវបញ្ចប់នៅពេលដែលការផ្តល់ការលើក ទឹកចិត្តត្រូវបានបញ្ចប់ដែរ ។

- **ការចូលរួមតាមមុខនាទី:**

  ប្រជាជនចូលរួមដោយបង្កើតជាក្រុមៗដើម្បីជួយ សំរេចបាននូវគោលបំណងនានាពាក់ពន្ធ័ទៅ និងគំរោង ។ពួកគេមិនមែនជាផ្នែកនៃការចាប់ផ្តើមគំរោងនោះទេ ហើយដែលអាច ទទួលបានតែនៅពេលអនុវត្តន៏តែប៉ុណ្ណោះដែរ ។

- **ការចូលរួមតាមបែបឆ្លងឆ្លើយ:**

  ប្រជាជនចូលរួមនៅក្នុង ការធ្វើវិភាគរួមគ្នាដែលនាំដល់ការរៀបចំកសាងផែនការសកម្មភាព ហេតុដូច្នេះហើយ ពួកគេមានចំណែកនៅក្នុងការថែទាំរចនាសម្ពន្ធ័ ឬការអនុវត្តន៏ ។

Copyright: Royal Government of Cambodia – GTZ supported:
Land Administration and Management Project (LMAP)

# ការរៀបចំកសាងផែនការតាមបែបការចូលរួម

## គោលការណ៍និងដំណើរការទូទៅ



▶ **ការរួបរួមគ្នាដោយខ្លួនឯង :**

ប្រជាជនចូលរួមដោយគំនិតផ្តួចផ្តើមខ្លួនឯងហើយមិនផ្អែកទៅ លើការចាប់ផ្តើម ពីខាងក្រៅឡើយ។ ពួកគេផ្អែកតែទៅលើប្រភពពីខាងក្រៅ សំរាប់ផ្តល់ថវិការឬជំនួយបច្ចេកទេសក៏ប៉ុន្តែរក្សាការគ្រប់គ្រងទៅលើការប្រើប្រាស់ធនធាន។ គំនិតផ្តួចផ្តើមក្នុងមូលដ្ឋានទាំងនេះមានពេលខ្លះនាំដល់ការផ្លាស់ប្តូរនូវអំណាច ហើយមានពេលខ្លះទៀតក៏ពុំមាន ដែរ ។

ពុំមានយុទ្ធវិធីណាមួយជាទូទៅដែលអាចប្រើសំរាប់រៀបចំការចូលរួមបានទេ។ បែបបទនៃការចូលរួមមានការ រៀបចំអាស្រ័យទៅនឹងកត្តា ច្រើនបែបណាស់ដែល កត្តាទាំងអស់នោះមិនអាចរៀបរាប់អស់បាន ទេនៅទីនេះ ។ក៏ប៉ុន្តែមានគោលការណ៍ និងដំណើរ ការទូទៅ មួយចំនួនតូចដែលគួរតែទទួលបានការស៊ើបអង្កេតនៅពេលរៀបចំទម្រង់ណា មួយនៃការចូលរួមក្នុងការរៀបចំកសាងផែនការ។

**ការចូលរួមត្រូវតែផ្អែកទៅលើតំលៃគំរូមួយចំនួន :**

- បុគ្គលនិមួយៗអាចរៀនសូត្រនិងអាចផ្លាស់ប្តូរបាន
- បុគ្គលនិងសហគមន៍និមួយៗអាចកំណត់បញ្ហានានានៅក្នុងជីវិតពួកគេ អាចរកឃើញនូវដំណោះស្រាយ និង អាច ធ្វើសកម្មភាពដើម្បីសំរេចបាននូវគោលបំណង ។
- ប្រជាជនអាចធ្វើការរួមគ្នាប្រកបទៅដោយប្រសិទ្ធិភាព ដើម្បីផ្លាស់ប្តូរលក្ខខណ្ឌនានាដែលស្ថិត នៅហួសពីការគ្រប់គ្រងរបស់ពួកគេ។
- ដោយការផ្លាស់ ប្តូរផ្នែកណាមួយនៃជីវិតរបស់ខ្លួនបុគ្គលអាចទទួលបាននូវផលប្រយោជន៍លើការផ្លាស់ប្តូរនោះ ហើយនាំឱ្យមានការកែលំអរដល់ស្ថានភាពរស់នៅរបស់ខ្លួន ។
- ការចូលរួមរបស់សហគមន៍ និងដំណើរការដោយខ្លួនឯង ជំរុញដល់ភាពរុងរឿងរបស់ពួកគេ ។
- បុគ្គលនិមួយៗមានចំណាប់អារម្មណ៍ពិតប្រាកដក្នុងការចូលរួមកសាងខ្លួន និងសហគមន៍របស់ពួកគេ ។

យុទ្ធវិធីជាជំហ៊ានៗខាងក្រោមកំណត់នូវការងារដែលត្រូវធ្វើ និងមិនត្រូវធ្វើមួយ ចំនួនដែលគួរតែគិតគូនៅពេលរៀបចំ ទំរង់នៃការចូលរួមកិច្ចការកសាងផែនការ ។

Copyright: Royal Government of Cambodia – GTZ supported:
Land Administration and Management Project (LMAP)

# ការរៀបចំកសាងផែនការតាមបែបការចូលរួម

## គោលការណ៍និងដំណើរការទូទៅ



### ១-សំរេចអ្នកដែលគួរចូលរួម :

សមាសភាពក្រុមរបស់ដំណើរការចូលរួមអាស្រ័យទៅលើកត្តាសំខាន និងគោលដៅដែលបានពិភាក្សា ឬឯក ភាពយល់ព្រម ។ សំរាប់ប្រធានបទខ្លះ ក្រុមមនុស្ស ដូចគ្នាមួយក្រុមនៃអ្នកចូលរួមត្រូវតែមានចំណែកនៅក្នុងក្រុមដ៏ទៃ ទៀត ក្រុមមនុស្ស មានលក្ខណៈផ្សេងៗគ្នានៃអ្នកចូលរួមត្រូវតែជ្រើសរើសឡើង (ខុសគ្នាទាំងផ្នែកគំនិត និងអាយុ )។ នៅពេលសំរេចអ្នកដែលគួរចូលរួមបុព្វហេតុរបស់ប្រជាជនគួរតែពិចារណា ។ករណីទាំងនេះអាចរួមទាំងចំណាប់អារម្មណ៏ទៅលើប្រធានបទឱកាសសំរាប់ការទាក់ទង ផ្នែកសង្គមឱកាសសំរាប់ទទួលបានពត៌មានភាពងឿយឆ្ងល់ការលើកទឹក ចិត្តផ្នែកហិរញ្ញវត្ថុមធ្យោបាយផ្សេងៗការជឿទុកចិត្តទៅលើអ្នករៀបចំដំណើរ ការចូលរួម។ សមាសភាពរបស់ក្រុមគឺជាធាតុផ្សំដ៏សំខាន់ សំរាប់ការចូលរួមប្រកបដោយជោគជ័យ ។

### ២-រៀបរាប់អំពីភារៈកិច្ចនិងតួនាទីរបស់អ្នកចូលរួម :

ភារៈកិច្ចមានភាពខុសៗគ្នាទៅតាមគោលបំណងនៃការចូលរួមប្រជុំ ។តួនាទីអាចមានភាពផ្សេងៗគ្នាពីតួនាទីប្រយោលរហូតដល់តួនាទីសកម្មផ្ទាល់អាស្រ័យទៅលើពេលវេលា ធនធាននិងមធ្យោបាយដែលមាន ។នៅក្នុងតួនាទីប្រ យោលអ្នកចូលរួមដែល ត្រូវបានអញ្ជើញឱ្យចូលរួមក្នុងដំណើរការដើម្បីពិភាក្សាកត្តាសំខាន់ជាក្រុម ។ ពុំចាំបាច់មានការ បង្ហាញឡើយ ។ នៅក្នុង ករណីរបស់តួនាទីសកម្ម អ្នកចូលរួមមានតួនាទីប្រហែលទៅនឹងតួនាទីនិងភារៈកិច្ចពិភាក្សាដូចជា សរសេររបាយការណ៏ រៀបចំការបង្ហាញកសាងសំនួរ រៀបចំកសាងជារូបភាព ។ល។

Copyright: Royal Government of Cambodia – GTZ supported:
Land Administration and Management Project (LMAP)

គោលការណ៍និងដំណើរការឆ្ពោះទៅ



### ៣-រៀបរាប់អំពីភារៈកិច្ចរបស់អ្នកសំរបសំរួលដំណើរការ :

អ្នកសំរបសំរួលអាចចូលរួមបញ្ចូល ជំនាញការ អ្នកកោះប្រជុំ អ្នកមានជំនាញផ្សេងៗ ប្រធាន និងអ្នកដឹកនាំ ។ អ្នកសំរបសំរួល គឺជាគន្លឹះដល់ការសំរេចជោគជ័យ សំរាប់បង្កើតបរិយាកាសល្អសំរាប់ការចូលរួម ។ អ្នកសំរបសំរួលជា អ្នកទទួលខុសត្រូវចំពោះដំណើរការតែមិនមែនចំពោះបរិបទនៃការពិភាក្សាទេ ។អ្នកសំរបសំរួលត្រូវតែសំរបទៅតាម គោលបំណងរបស់ ក្រុម ហើយត្រូវមានជំនាញទាំងអស់ដែលចាំបាច់ដឹកនាំដំណើរការប្រកបទៅដោយប្រសិទ្ធិភាព។ អ្នកសំរបសំរួលគឺជាអ្នកមានការហ្វឹកហ្វឺនបានល្អនៅក្នុងក្រុមឌីណាមិច មានជំនាញច្បាស់លាស់ក្នុងការងារសំភាសន៍មាន សម្ថត្ថភាពដើម្បីណែនាំក៏ប៉ុន្តែមិនមែនគ្របដណ្តប់ការពិភាក្សានោះទេ។ អ្នកសំរបសំរួលមិនត្រូវធ្វើការវាយតំលៃឬប្រើប្រាស់ភាសាកាយវិការដែលនាំឱ្យមានការអនុមត័ឬមិនអនុមត័នោះទេ។ អ្នកសំរបសំរួលត្រូវតែអាចទទួលយកមកគិតគូរនូវគ្រប់ការផ្តល់យោបល់នានាត្រូវតែជំរុញគ្រប់អ្នកចូលរួមឱ្យចូលរួមពិភាក្សា ។

- ត្រូវតែមានទស្សនៈល្អនូវអ្វីដែលបានពិភាក្សានិងមានសមត្ថភាពរៀបចំនូវរូបភាពទាំងនេះបាន ឆាប់ រហ័ស និង មានប្រសិទ្ធិភាព ។
- ត្រូវមានជំនាញផ្នែកសន្ទនាច្បាស់លាស់ដោយការសួរសំនួរចំៗការផ្តល់សេចក្តីសង្ខេបខ្លីៗ និងមតិចូលរួម ត្រឹមត្រូវដើម្បីឱ្យអ្នកចូលរួមទាំងអស់ អាចយល់បាន ល្អនូវអ្វីដែល កំពុងតែកើតមាន ។
- ត្រូវតែមានគោលជហ៊រអាព្យាក្រិត្យ ដើម្បីឱ្យអ្នកសំរបសំរួលអាច ជាតំណាងឱ្យគ្រប់ទស្សនៈទាំង អស់នៅក្នុង បែបបទមួយអាព្យាក្រិត្យ ។

Copyright: Royal Government of Cambodia – GTZ supported:
Land Administration and Management Project (LMAP)

# ការរៀបចំគំរោងផែនការតាមបែបការចូលរួម

## គោលការណ៍និងដំណើរការនានា



**៤-សំរេចថាតើការប្រជុំមួយឬច្រើនដែលជាការចាំបាច់:**

អាចទាម ទារឱ្យមានការប្រជុំច្រើនបែបផ្សេងៗគ្នា ដោយការងារនេះ ចាំបាច់ត្រូវតែរៀបចំជាផែនការដោយប្រុង ប្រយត្ន័ ។ការបែងចែកនៅក្នុងប្រធានបទដែលត្រូវតែលើកយកមកសិក្សា និងពេលវេលាត្រូវតែមានការអនុមត័ សំរេច ។វាក៏ជាការចាំបាច់ដើម្បី សំរេចទៅ លើសមាសភាពរបស់ក្រុមនិមួយៗសំរាប់ការប្រជុំផ្សេងៗ ។

**៥-ការសំរេចទៅលើពេលវេលានិងភារៈកិច្ចដែលត្រូវការ :**

រយៈពេលនៃការប្រជុំអាចមានរយៈពេលផ្សេងៗគ្នាពេលវេលាប្រជុំនិមួយៗ និងទូទៅត្រូវតែមាន ការរៀបំជា ផែនការដោយប្រុងប្រយត្ន័។ទីតាំងសំរាប់ការប្រជុំក៏មានសារៈសំខាន់ណាស់ដែរ។ ទីតាំងប្រជុំត្រូវឆ្លុះបញ្ចាំងពីប្រភេទ នៃបរិយាកាស ដែលត្រូវការផ្អែក ទៅលើទស្សនៈរបស់គោលដៅ នៃដំណើរការប្រភេទអ្នកចូលរួម និងវីធីសាស្រ្តនៃការ ចូលរួមដែលប្រើប្រាស់។ សំភារៈគាំទ្រដែលអាចប្រើប្រាស់រួមមានមេរៀនការបង្ហាញតាមម៉ាស៊ីនកុំព្យូទ័រខ្សែភាពយន្តសន្លឹកពតិមាន ពិត ផែនទីគំនូសបំព្រួញ រូបភាព ។ល។

៦-ការកំណត់ពីទិន្នផល :

ទិន្នផលនៃកិច្ចប្រជុំតាមបែបចូលរួម ត្រូវតែកំណត់ ។ទិន្នផល អាចជាគំនូសបំព្រួញសាមញ្ញ រូបភាព គំនូរជា របាយការណ៍ជាសំនួរជាច្រើនដែលទាមទារឱ្យមាន ការបកស្រាយបន្ត ទៀត ។ល។ គោលដៅ និងប្រភេទនៃអ្នកចូលរួម កំណត់នូវផលិតផលចុងក្រោយ របស់ដំណើរការ។ អ្នកចូលរួមខ្លះចូលចិត្តអានរបាយការណ៍ចំណែកអ្នកខ្លះទៀតចូលចិត្ត រូបភាពគំនូរ ។

**៧-សំរេចលើការប្រមូលទិន្នន័យដែលត្រូវការ:**

នៅក្នុងកំឡុងពេលនៃដំណើរការចូលរួមអាចជាការចាំបាច់ឱ្យមានការប្រមូលទិន្នន័យនិងពតិមាន។ ការងារនេះ អាចធ្វើឡើង ដោយអ្នកសម្របសម្រួល ចំណែកក្រុមការងារទាំងមូល អាច រៀបចំជារូបភាពនូវលទ្ធផលនៃការប្រុង ប្រយត្ន័របស់ពួកគេ ។ អ្នកសង្កេតការ អាចជួយកត់ ត្រានូវលទ្ធផលនៃដំណើរការ ។ គួរតែមានការប្រមូលយកពតិមាន នៅពេលប្រជាជនធ្វើការឆ្លើយឆ្លងទៅវិញទៅមក (ដូចជាការ គ្របដណ្តប់ដោយ បុគ្គលបរិយាកាសតាមក្រុម ។ល ។) រចនាសម្ពន្ឋ័ នៃការរើកញែកដែលបានលើកឡើងដំណើរការសម្របសម្រួល វិធីដែលអ្នកចូលរួមប្រើប្រាស់សំភារៈ វិធីដែលទិន្នផល ឬ លទ្ធផលចុងក្រោយទទួលបាន ។


Copyright: Royal Government of Cambodia – GTZ supported:
Land Administration and Management Project (LMAP)

## References and Sources Used



Jenssen, B.;(ed), **Planning as a Dialogue,** District Development Planning and Management in Developing Countries, SPRING Research Series Nr. 2, Dortmund, 1992

Jenssen, B.; **Towards a Quantification of Agglomeration Disadvantages in Metroploitan Areas of Developing Countries**, University of Dortmund, IRPUD, 1984

Rondinelli, Dennis, A.: **Applied Methods of Regional Planning: The Urban Functions in Rural Development Approach**, Clark University: Rural Marketing Centers Working Group (USAID), 1983a

Thimm, Hr.R., Green, D.A.G., Leupolt, M. (Eds); P**lannning and Operating Rural Centres in Developing Countries,** Studien zur Ländlichen Entwicklung. No. 18, 1986

Copyright: Royal Government of Cambodia – GTZ supported:
Land Administration and Management Project (LMAP)